THE SCHOOL DISTRICT OF PHILADELPHIA

**OFFICE OF THE SUPERINTENDENT**
440 North Broad Street
Philadelphia, PA 19130

**William R. Hite, Jr., Ed.D.**
Superintendent

ថ្ងៃទី 12 ខែមេសា ឆ្នាំ 2021

មាតាបិតា និងគ្រួសារសិស្សនៃមណ្ឌលសាលា Philadelphia ជាទីមេត្រី!

យើងដឹងថា ឆ្នាំនេះពោរពេញទៅដោយភាពមិនច្បាស់លាស់ជាច្រើនចំពោះគ្រួសាររបស់យើង ដូច្នេះយើងចង់ចែករំលែកព័ត៌មានសំខាន់ៗមួយចំនួនអំពីចំណុចអ្វីខ្លះដែលអ្នកអាចរំពឹងទុកបាន សម្រាប់រយៈពេលនៅសល់នៃឆ្នាំសិក្សានេះ។

**<u>ផែនការសិក្សាតាមប្រព័ន្ធកូនកាត់ ការអនុវត្តដំណាក់កាលទី III</u>**
សម្រាប់ដំណាក់កាលទី III សិស្សនៅក្នុងក្រុមខាងក្រោម នឹងអាចជ្រើសយកការសិក្សាតាមប្រព័ន្ធកូនកាត់បាន ចាប់ពីសប្តាហ៍ថ្ងៃចន្ទ ទី 10 ខែឧសភា ឆ្នាំ 2011៖
- សិស្សទាំងអស់ក្នុងថ្នាក់ទី 6-9 ដែលមិនទាន់បានត្រឡប់មកសាលារៀនវិញ និង
- សិស្សមានសេចក្តីត្រូវការស្មុគស្មាញក្នុងថ្នាក់ទី 10-12។

*ការស្ទង់មតិអំពីការជ្រើសរើសការសិក្សាតាមប្រព័ន្ធកូនកាត់ ដំណាក់កាលទី III* នឹងបើកនៅថ្ងៃអង្គារ ទី 20 ខែមេសា ហើយបិទនៅថ្ងៃអង្គារ ទី 27 ខែមេសា។ គ្រួសារសិស្សក្នុងដំណាក់កាលទី III នឹងទទួលបានអ៊ីម៉ែលមួយ ដែលមានសេចក្តីណែនាំអំពីរបៀបចុះឈ្មោះ។ ប្រសិនបើអ្នកជ្រើសយកការសិក្សាតាមប្រព័ន្ធកូនកាត់ កូនរបស់អ្នកនឹងត្រូវបានគេកំណត់នូវកាលវិភាគមួយ ដោយត្រូវទៅសាលារៀនដោយផ្ទាល់ពីរថ្ងៃក្នុងមួយសប្តាហ៍ និងសិក្សាតាមប្រព័ន្ធឌីជីថលបីថ្ងៃក្នុងមួយសប្តាហ៍ ចាប់ពីសប្តាហ៍ថ្ងៃចន្ទ ទី 10 ខែឧសភា ឆ្នាំ 2021។ ដើម្បីត្រៀមទទួលស្វាគមន៍សិស្ស បុគ្គលិកទាំងអស់នឹងវិលត្រឡប់មកអគារសាលារៀនវិញនៅថ្ងៃចន្ទ ទី 26 ខែមេសា។ សហព័ន្ធគ្រូបង្រៀនទីក្រុង Philadelphia នឹងបំពេញការពិនិត្យកិច្ចត្រៀមលក្ខណៈរបស់អគារសាលារៀនទាំងអស់ឲ្យបានចប់សព្វគ្រប់ មុនពេលបុគ្គលិកវិលត្រឡប់មកវិញ។ សម្រាប់សេចក្តីលម្អិត សូមចូលទៅ philasd.org/aes។

ដំណាក់កាលទី III នឹងជាដំណាក់កាលចុងក្រោយនៃផែនការសិក្សាតាមប្រព័ន្ធកូនកាត់សម្រាប់ឆ្នាំសិក្សានេះ។ សិស្សមិនស្ថិតក្រោមផែនការ រហូតដល់ដំណាក់កាលទី III នេះ នឹងត្រូវបន្តសិក្សាតាមប្រព័ន្ធឌីជីថល 100% សម្រាប់រយៈពេលនៅសល់នៃឆ្នាំសិក្សានេះ។

**<u>ពិធីបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យ និងពិធីចុងឆ្នាំផ្សេងទៀត (EOY)</u>**
យើងដឹងថា ការរក្សាគម្លាតពីមិត្តភ័ក្តិ និងគ្រូបង្រៀននៅសាលារៀន គឺជារឿងលំបាក ជាពិសេសចំពោះសិស្សវិទ្យាល័យថ្នាក់ចុងក្រោយរបស់យើង ដែលបានស្រមៃចង់បានស្ថានភាពផ្សេងនៃឆ្នាំចុងក្រោយនៅវិទ្យាល័យ។ ខណៈគ្មានអ្វីអាចប៉ះប៉ូវបទពិសោធន៍របស់អ្នកក្នុងឆ្នាំកន្លងទៅ យើងមានសេចក្តីរីករាយ សូមប្រកាសថា៖
- អ្នកនឹងអាចប្រារព្ធពិធីប្រកបដោយសុវត្ថិភាពដោយផ្ទាល់ជាមួយមិត្តភ័ក្តិ និងគ្រួសាររបស់អ្នក (ដែលអនុញ្ញាតឲ្យធ្វើទៅបាន ផ្អែកលើដែនកម្រិតសុវត្ថិភាពនៃចំនួនមនុស្ស) នៅក្នុងពិធីបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យនៅក្រៅអគារ ដរាបណាស្ថានភាពជំងឺកូវីដ-19 អនុញ្ញាតឲ្យប្រមូលផ្តុំដោយសុវត្ថិភាពនៅសាលារៀន និង

- ជាកាដូរពិសេស មណ្ឌលសាលា នឹងផ្តល់ជូនដោយឥតគិតថ្លៃនូវមួក និងអាវបញ្ចប់ការសិក្សាដល់សិស្ស ថ្នាក់ចុងក្រោយនៅវិទ្យាល័យ នៅក្នុងថ្នាក់ឆ្នាំ 2021 ដែលបានបញ្ចប់ការសិក្សា។ ប្រសិនបើអ្នកបានបង់ ថ្លៃមួក និងអាវបញ្ចប់ការសិក្សារួចហើយ អ្នកនឹងទទួលបានប្រាក់បង្វិលសងវិញ។ សាលារៀននឹងចែក រំលែកសេចក្តីលម្អិតបន្ថែមទៀត ពេលណាគេបានសម្រេចចុងក្រោយលើនីតិវិធី។

នាយកនៅសាលារៀន ដែលមានសិស្សត្រូវឡើងថ្នាក់ នឹងមានលទ្ធភាពបត់បែនក្នុងការរៀបចំពិធី ឡើងថ្នាក់ប្រកបដោយសុវត្ថិភាព។ ពិធីចុងឆ្នាំផ្សេងទៀត អាចត្រូវបានសម្របសម្រួលដោយក្រុមថ្នាក់ដឹកនាំតាម សាលារៀននីមួយៗ។

រាល់សកម្មភាពពិធីចុងឆ្នាំទាំងអស់ នឹងត្រូវរៀបចំនៅក្រៅអគារ ហើយត្រូវគោរពយ៉ាងម៉ឺងម៉ាត់តាមគោលការណ៍ ណែនាំស្តីពីសុវត្ថិភាព ដែលបង្កើតដោយនាយកដ្ឋានសុខភាពសាធារណៈទីក្រុង Philadelphia ដែលរួមបញ្ចូលៈ ការពាក់ម៉ាស់ជាសាកល ការពិនិត្យសុខភាពដោយអ្នកចូលរួមខ្លួនឯងមុនពេលចូលរួមក្នុងពិធី និងការ រក្សាគម្លាតសុវត្ថិភាព។

<u>**ការសិក្សាដោយផ្ទាល់ក្នុងរដូវក្តៅ និងឱកាសបង្កើនជំនាញ**</u>

យើងក៏កំពុងតែផ្តល់ជូនសិស្សគ្រប់អាយុ និងគ្រប់កម្រិតថ្នាក់នូវឱកាសផ្សារភ្ជាប់ជាមួយមិត្តភ័ក្តិ ដោយផ្តល់ជូននូវ កម្មវិធីសិក្សាដោយផ្ទាល់ និងកម្មវិធីបង្កើនជំនាញជាច្រើនក្នុងរដូវក្តៅនេះ។ មានកម្មវិធីសម្រាប់សិស្សគ្រប់រូប។ សេចក្តីលម្អិតអំពីកម្មវិធីទាំងនេះ និងរបៀបចុះឈ្មោះកូនរបស់អ្នក នឹងត្រូវផ្ញើជូនអ្នក ឬអ្នកអាចរកបាននូវសេចក្តី លម្អិតនៅត្រង់នេះ។

ខ្ញុំសង្ឃឹមថា ព័ត៌មាននេះជួយអ្នករៀបចំផែនការជាមុនសម្រាប់រយៈពេលនៅសល់នៃឆ្នាំសិក្សានេះ និង ផ្តល់ជូនអ្នកនូវការរំពឹងទុក នាប៉ុន្មានសប្តាហ៍ និងខែខាងមុខ។ សូមអរគុណអ្នកដែលបានបន្តធ្វើជាដៃគូដ៏អស្ចារ្យ ក្នុងការអប់រំកូនរបស់អ្នក។

ដោយសេចក្តីស្មោះសរ!



William R. Hite Jr., Ed.D.
នាយក
មណ្ឌលសាលា Philadelphia